# បច្ចុប្បន្នភាពជម្ងឺគ្រុនឈាម៤៣សប្តាហ៍*ដើមឆ្នាំ*២០១៤

**ដោយ វេជ្ជ.ហ៊ុយ រ៉េកុល**

ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្រ្ត-បាណកសាស្រ្ត

(ការបរិច្ឆេទរបាយការណ៍ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ២០១៤)

## សភាពការណ៍ថ្មីៗ

ជម្ងឺគ្រុនឈាមនៅក្នុង៤៣សប្តាហ៍ដើមឆ្នាំ២០១៤នេះ មានចំនួន៣.០៩១ករណី (អត្រាអាំងស៊ីដង់មាន ១០០ ក្នុងចំណោមមនុស្ស ១០០ពាន់នាក់) ដែលក្នុងនោះស្លាប់មាន ចំនួន១៩ករណី (អត្រាស្លាប់មាន ០,៦%) បានន័យថា ករណីឈឺនាពេលនេះបានថយចុះចំនួន ៨១.៤% បើប្រៀបធៀបរយៈពេលដូចគ្នានឹងឆ្នាំ២០១៣ ដែលមានចំនួន១៦.៦៤០ករណី ក្នុងនោះករណីស្លាប់មានចំនួន៥៣នាក់។ អត្រាឈឺ/ស្លាប់ធ្លាក់មកដល់កក់រិតទាបគួរអោយកត់សំគាល់ បើប្រៀបអត្រារយៈពេលដូចគ្នានៅបណ្តាឆ្នាំមុនៗចាប់តាំងពីឆ្នាំ២០១១កន្លងមក (សូមអានតារាងខាងក្រោម)។ ទាំងករណីឈឺ និងស្លាប់កំពុងជានាបានជោគជ័យ បើប្រៀបធៀបនឹងសុចនាករឆ្នាំ ២០១៤ (អត្រាករណីឈឺ≤៣១៩ និងអត្រាស្លាប់ ≤ ០,៦%) ។

និន្នាការថ្មីដែលគួរកត់សំគាល់ផងដែរក្នុងអំឡុង ៣ ឆ្នាំចុងក្រោយនេះ គឺករណីគ្រុនឈាមហាក់កំពុងកើនឡើងលើមនុស្សធំអាយុចាប់ពី១៥ឆ្នាំឡើង ដូចជាដើមឆ្នាំ២០១៤នេះ មាន ៤,៣% នៃករណីគ្រុនឈាមសរុប ដែលក្នុងកំឡុងឆ្នាំ២០០៧ - ២០១៣ មានតែ២ ឬ ៣% ប៉ុណ្ណោះ (នេះមិនមែនមានន័យថា ចំនួនករណី គ្រុនឈាមមានការកើនឡើងបន្ថែមពីលើករណីសរុបនោះទេ ប៉ុន្តែវាជាការប្រែប្រួលសមាមាត្រគិតជាភាគរយនៃ គ្រុនឈាមសរុបទាំងអស់ ដែលកំពុងតែបានថយចុះចំពោះកុមារទៅវិញនោះទេ ដែលជាលទ្ធផលសបញ្ជាក់អោយ ឃើញថាប្រជាជនក្នុងប្រទេសកម្ពុជាកំពុងទទួលបានផលវិជ្ជមានពីសេវាសុខាភិបាលលើការងារលើកកំពស់ សមត្ថភាពចំណេះដឹងសហគមន៍ពិសេសសិស្សសាលាដែលការពារកុមារភាពអោយគេចផុតពីការចំលងជំងឺបាន)។

ទោះបីជាករណីជំងឺគ្រុនឈាមឆ្នាំនេះទាប ឬថយចុះយ៉ាងណាក៏ដោយ គឺយើងនៅតែ ត្រូវបន្តប្រុងប្រយ័ត្នជានិច្ច ព្រោះថាវដ្តវិយាបថជំងឺគ្រុនឈាមនៅកម្ពុជាកន្លងមករាល់ ៣ ទៅ ៥ឆ្នាំម្តង នឹងមានការផ្ទុះរាតត្បាតម្តង ដូចជានៅឆ្នាំ ១៩៩៨ (ករណីឈឺ១៦.២១៦ និងស្លាប់៤៧៥នាក់) ឆ្នាំ២០០៧ (ករណីឈឺចំនួន៣៩.៤៦០ និង ស្លាប់ ៤០៤នាក់) និងឆ្នាំ២០១២ (ករណីឈឺ៤០.៩០៩ និងស្លាប់១៨៩នាក់) បានន័យថាការផ្ទុះរាតត្បាតម្តង ទៀតនឹងអាចកើតមាននៅឆ្នាំណាមួយនៃឆ្នាំ ២០១៥ ដល់ ២០១៧។

## ស្ថិតិជម្ងឺគ្រុនឈាម ៤៣សប្តាហ៍ដើមឆ្នាំ ២០០៦ - ២០១៤




## សារបានអន្តរាគមន៍នៅកម្ពុជា

អន្តរាគមន៍គន្លឹះសំរាប់ឆ្លើយតបនឹងជម្ងឺគ្រុនឈាមគឺ បំបាត់ប្រភពនិងជំរកមូសខ្លា និងបញ្ជូនអ្នកជម្ងឺក្តៅខ្លួន (ជាពិសេសកុមារ) ទៅមន្ទីរពេទ្យសាធារណៈអោយបានទាន់ពេល ហើយទង្វើអន្តរាគមន៍ទាំងនេះត្រូវចាប់ផ្តើមដំបូងបង្អស់ពី**បុគ្គលនិងគ្រួសារនីមួយៗ បន្តមកគឺការចូលរួមរបស់សហគមន៍នីមួយៗ**។ អាស្រ័យហេតុនេះ ខ្ញុំសូមអំពាវនាវដោយទទូចសំណូមពរដល់ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងបណ្តាញសារព័ត៌មានទាំងអស់មេត្តាជួយជំរុញចលនាទាំងនេះដើម្បីបញ្ចៀសកុមារពីគ្រោះមរណៈដោយសារការផ្ទុះរាតត្បាតគ្រុនឈាម។

ក្នុងដើមឆ្នាំនេះ **៦៩%នៃករណីគ្រុនឈាមសរុប**គឺជាកុមារអាយុពី៥ដល់១៤ឆ្នាំ ដែលភាគច្រើនកំពុងរៀនក្នុងសាលា ហេតុនេះការចូលរួមរបស់លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស ជាផ្នែកមួយសំខាន់ខ្លាំងណាស់ក្នុងការប្រយុទ្ធនឹងជម្ងឺ គ្រុនឈាម ព្រោះថា ការយល់ដឹងរបស់សិក្សានុសិស្សពីជម្ងឺគ្រុនឈាមមានប្រយោជន៍ដល់ សាម៉ីខ្លួនផង មាតា បីតាផង និងបងប្អូនរបស់ពួកគេនៅផ្ទះផង ក៏ដូចជាសហគមន៍ទាំងមូលផង ។




## សារបានទូទៅ

ជម្ងឺគ្រុនឈាមបង្កដោយ "វីរុសដាំង" ដែលចម្លងពីមនុស្សម្នាក់ទៅម្នាក់ទៀតដោយមូសខ្លាញីខាំ យោងតាមឯកសារអង្គការសុខភាពពិភពលោក មានការសិក្សាស្រាវជ្រាវដើម្បីបង្កើតវ៉ាក់សាំងការពារ ឬ ឱសថប្រឆាំងវីរុស គ្រុនឈាមជាច្រើនក្នុងពេលបច្ចុប្បន្ននេះ ប៉ុន្តែនៅមិនទាន់មានបេក្ខភាពវ៉ាក់សាំងណាមួយត្រូវបានណែនាំអោយ ប្រើប្រាស់ជាផ្លូវការនៅឡើយទេ ហេតុនេះសំរាប់ជម្ងឺគ្រុនឈាមជាការសំខាន់គឺ ការព្យាបាលសម្រន់រោគសញ្ញាជម្ងឺ តែប៉ុណ្ណោះ។

មានប្រជាជនប្រហែល២.៥០០លាននាក់កំពុងប្រឈមនឹងការឆ្លងវីរុសគ្រុនឈាម ក្នុងនេះ៧០%នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ **តាមការប្រកាសលទ្ធផលស្រាវជ្រាវថ្មីៗ**របស់សកលវិទ្យាល័យអុកស្វឺត និងមូលនិធិ វែលខាំ ត្រាស់ក្នុងមួយឆ្នាំៗប្រជាជនប្រហែល៣៩៦លាននាក់ ក្នុងសកលលោក**បានឆ្លង**វីរុសគ្រុនឈាមក្នុងនេះមាន ៩៦លាននាក់ ( ១ភាគ៤ ) មានរោគសញ្ញាដែលតម្រូវអោយចូលសំរាកពេទ្យ ហើយមានប្រហែល២៩៤លាននាក់ ជាអ្នកបានឆ្លងវីរុសគ្រុនឈាម ប៉ុន្តែអ្នកខ្លះគ្មានចេញជារោគសញ្ញា ឯអ្នកខ្លះមានស្តែងចេញរោគសញ្ញាស្រាលឬធ្ងន់។ តាមទិន្នន័យនេះ កាលណាឃើញមាន**កុមារមួយនាក់ចូលសំរាកពេទ្យ**ដោយសាររោគសញ្ញាគ្រុនឈាមនោះ យើង អាចប៉ាន់ស្មានបានថា នៅមជ្ឈដ្ឋានដែលកុមាររស់នៅអាចមានអ្នកដែលបានឆ្លងវីរុសគ្រុនឈាមប្រហែល **៣នាក់** ប៉ុន្តែ ៣ នាក់នេះ អាចអ្នកខ្លះមានរោគសញ្ញា ឬ គ្មានរោគសញ្ញាទាំងអស់ ហើយអ្នកដែលគ្មានរោគសញ្ញាទាំងអស់ នោះនឹង

ក្លាយជាភ្នាក់ងារផ្ទុកវីរុសដោយមិនដឹងខ្លួន សំរាប់អោយភ្នាក់ងារចំលងជំងឺហៅថា មូសខ្លា (ញី) អាចខាំ ចម្លងទៅអ្នកដ៏ទៀតបានយ៉ាងងាយពី២ទៅ៣នាក់ទៀត។ ដូច្នេះ បើឃើញមានករណីគ្រុនឈាមចូលសំរាកពេទ្យ កាន់តែច្រើន គឺហានីយភ័យក្នុងការឆ្លងជំងឺ ក៏មានកំរិតកាន់តែខ្ពស់ផងដែរសំរាប់ សហគមន៍ដែលអ្នកជម្ងឺទាំងនោះ រស់នៅ។ តាមរបាយការណ៍អង្គការសុខភាពពិភពលោក ទិន្នន័យសរុបករណីឈឺក្នុង៣តំបន់គឺ អាមេរិក អាស៊ីអាគ្នេយ៍ និងប៉ាស៊ីហ្វិកខាងលិចបានកើនឡើងប្រហែល៩០%ក្នុងរយៈកាលតែ២ឆ្នាំគឺ ឆ្នាំ២០០៨ - ២០១០។ ដោយឡែកក្នុងតំបន់អាស៊ាននាទសវត្សឆ្នាំ២០០០-២០១០ ចំនួនករណីគ្រុនឈាមកើន១៩% ក្នុងមួយឆ្នាំៗ ក្នុងនោះកម្ពុជាកើន ១០% ក្នុងមួយឆ្នាំ។